របាយការណ៍ស្ដីអំពី ការជួញដូរមនុស្ស

ចេញផ្សាយដោយ ការិយាល័យត្រួតពិនិត្យ និងបង្រ្កាបការជួញដូរមនុស្ស

ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤

២. ការអនុវត្តន៍ល្អបំផុតជាអន្តរជាតិ

កិច្ចប្រឹងប្រែងមួយចំនួនដែលនាំមកនូវគំនិតថ្មីៗក្នុងការទប់ស្កាត់ការជួញដូរមនុស្ស បានលេចចេញជារូបរាងនៅក្នុងកំលុងពេលនៃការរៀបចំរបាយការណ៍ស្ដីពីការជួញដូរមនុស្សប្រចាំឆ្នាំ២០០៤ និងតាមរយៈទំនាក់ទំនងរបស់ក្រសួងការបរទេសអាមេរិកជាមួយនឹងរដ្ឋាភិបាលបរទេស និងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិក្នុងរយៈពេលពេញមួយឆ្នាំ ។ ភាគច្រើននៃកិច្ចខំប្រឹងប្រែងទាំងនេះមានលក្ខណៈពិសេសគួរអោយកត់សំគាល់ត្រង់ដែលថា វាបានបង្ហាញនូវវិធានការណ៍ប្រឆាំងនឹងការជួញដូរមនុស្សដែលមាននិរន្តភាពនិងចំនាយថវិការតិច ។ សកម្មភាពនិងកម្មវិធីទាំងនេះត្រូវបានកត់សំគាល់នៅក្នុងរបាយការណ៍នេះថាជាការអនុវត្តន៍ល្អបំផុត ពីព្រោះវាបាននាំមកនូវគំនិតថ្មីៗនិងប្រកបដោយប្រឌិតញាណ វាធ្វើអោយមានការផ្លាស់ប្តូរជាក់ស្តែងជាវិជ្ជមាន វាមានចេរភាព ហើយវាមានសក្តានុពលសំរាប់អោយប្រទេសដទៃចំលងយកតាម ។

នៅចុងឆ្នាំ២០០៣តុលាការប្រទេសកម្ពុជាបានរកឃើញថា អ្នកជួញដូរឈ្មោះ សុងឡាងនេះ មានទោសពីបទទាសកម្មក្មេងស្រី (ដែលនៅឆាងស្តាំ) ហើយត្រូវជាប់គុក២០ឆ្នាំ ។

អង្គការបេសកកម្មយុត្តិធមិអន្តរជាតិ ដែលជាអង្គការក្រៅរដ្ឋាភិបាលអាមេរិកមួយ បានធ្វើការស៊ើបអង្កេតលើស្ថានភាពរបស់ពួកគេ ហើយដោយរួមសហការជាមួយមន្ត្រីអនុវត្តច្បាប់កម្ពុជា បានចូលរួមក្នុងការបង្រ្កាបមួយ ដែលរំដោះបានកុមាន៣៧ នាក់ ។

<u>ការទប់ស្កាត់ទេសចរណ៏ផ្លូវភេទ</u> រដ្ឋាភិបាលប្រទេសប៉ាណាមាបានអនុម័តច្បាប់ប្រឆាំងការជួញដូរមនុស្សថ្មីមួយដែលដោះស្រាយការជួញដូរមនុស្សនៅក្នុងបរិបទនៃរូបភាពអាសគ្រាមកុមារ ទេសចរណ៏ផ្លូវភេទ និងការប្រើប្រាស់អ៊ីនធើណេត ។ នៅក្នុងចំនោមលក្ខណៈពិសេសដទៃទៀត ច្បាប់នេះបានតំរូវអោយ

អាកាសចរណ៍ ភ្នាក់ងារទេសចរណ៍ និងសណ្ឋាគារផ្តល់ពត៌មានជាលាយលក្ខណ៍អក្សរទៅដល់អតិថិជនអំពីការហាមឃាត់នៅក្នុងច្បាប់ថ្មីនេះ ។

ការស្កាត់ជួយអ្នកដែលអាចក្លាយជាជនរងគ្រោះ រដ្ឋាភិបាលប្រទេសកូឡុមប៊ីបានផ្តល់អំនាចទៅក្រសួងសន្តិសុខរដ្ឋបាលរបស់ខ្លួន ក្នុងការកំនត់និងធ្វើទំនាក់ទំនងទៅអ្នកដំណើរទៅក្រៅដែលទំនងនឹងអាចក្លាយជា ជនរងគ្រោះដោយការជួញដូរនៅអាកាសយានដ្ឋានមុនពេលដែលគេឈានជើងឡើងជិះយន្តហោះទៅក្រៅប្រទេស ។ មន្ត្រីនៃក្រសួងនេះព្យាយាមប្រាប់ទៅអ្នកដែលអាចក្លាយជាជនរងគ្រោះអំពីគ្រោះថ្នាក់នៃការជួញដូរ និងអំពីការក្លែងបន្លំថាផ្តល់ការងារដែលបានប្រាក់ច្រើន ។ នៅឆ្នាំ២០០៣ មានអ្នកដែលអាចក្លាយជាជនរងគ្រោះ៩នាក់ ត្រូវបានគេបញ្ចុះបញ្ចូលអោយជឿថា ការងារដែលគេត្រូវបានផ្តល់អោយនោះគឺជាការក្លែងបន្លំ ហើយគេក៏ឈប់ឡើងយន្តហោះធ្វើដំនើរទៅក្រៅប្រទេសទៅ ។

សហប្រតិបត្តិការរវាងប្រទេសដែលជាច្រកឆ្លងកាត់និងប្រទេសគោលដៅ រដ្ឋាភិបាលប្រទេសអ៊ីតាលីបានផ្តល់មូលនិធិទៅ "គំរោងចិកស៊ីល្បៀ២០០២" របស់រដ្ឋាភិបាលប្រទេសម៉ូរូកូ ។ គំរោងនេះផ្តល់ជំនួយដល់គំរោងតូចៗនៅក្នុងតំបន់គូរីបា ដែលគេស្គាល់ថាជាតំបន់ដែលមានពាក់ព័ន្ធក្នុងការធ្វើអន្តោប្រវេសន៍ដោយសំងាត់ទៅប្រទេសអ៊ីតាលី ។ គំរោងនេះមានបំនងផ្តល់ការងារដែលបានប្រាក់កំរៃច្រើនក្នុងប្រទេសម៉ូរូកូដើម្បីទប់ស្កាត់ជនរងគ្រោះពីការជួញដូរ ។ សំរាប់ជនរងគ្រោះដែលបានទៅដល់ប្រទេសអ៊ីតាលីហើយ ច្បាប់ប្រឆាំងការជួញដូរថ្មីរបស់ប្រទេសនេះបានបង្កើតអោយមានខ្ទង់ថវិកាដោយឡែកមួយសំរាប់កម្មវិធីជួយជនរងគ្រោះ ហើយរដ្ឋាភិបាលកណ្តាលបានផ្តល់៧០ភាគរយនៃមូលនិធិជំនួយនេះ ដោយអោយរដ្ឋាភិបាលប្រចាំតំបន់និងមូលដ្ឋានផ្តល់៣០ភាគរយដែលនៅសល់ ។

ការផ្តោតគោលដៅលើការជួញដូរផ្លូវភេទ កាលពីខែមករាឆ្នាំ២០០៤ ក្រុមប្រឹក្សាទីក្រុងម៉ាឌ្រីដ បានប្រកាសអំពីកិច្ចប្រឹងប្រែងយ៉ាងទូលំទូលាយមួយក្នុងការប្រឆាំងនឹងពេស្យាចារ និងការជួញដូរ ។ គំរោងនោះរួមមានៈ ការទប់ស្កាត់ ការបណ្តុះបណ្តាល ជំនួយដល់ជនរងគ្រោះ និងសកម្មភាពរបស់ប៉ូលីសប្រឆាំងនឹងអតិថិជន ។ ដោយផ្អែកទៅលើគោលការណ៍ថា វិធីដែលល្អបំផុតក្នុងការប្រឆាំងនឹងការជួញដូរក្នុងបំនងកេងប្រវ័ញ្ចផ្លូវភេទគឺត្រូវផ្តោតការយកចិត្តទុកដាក់លើអតិថិជនក៏ដូចជាជនរងគ្រោះនោះ កិច្ចប្រឹងប្រែងនេះបានស្វែងរកការគាំទ្រពីរដ្ឋាភិបាលស៊ុយអែតក្នុងការបង្កើតឧបករណ៍សំរាប់អនុវត្តច្បាប់ ។

ការប្រយុទ្ធប្រឆាំងនឹងទំលាប់បូរាណ ទំលាប់ចាស់នៃការ "មើលថែរក្សាក្មេង" របស់ពួកអាហ្វ្រិកបានចូលរួមដោយផ្ទាល់ក្នុងការជួញដូរមនុស្ស ។ ការជួញដូរកុមារចាប់ផ្តើមឡើងពីការរៀបចំក្នុងលក្ខណៈ

ឯកជនរវាងអ្នកជួញដូរនិងសមាជិកម្នាក់ក្នុងគ្រួសារ ដែលត្រូវជំរុញដោយស្ថានភាពសេដ្ឋកិច្ចដ៏យ៉ាបយឺនរបស់គ្រួសារនោះនិងតំរូវការរកប្រាក់ចំនេញនិងកំលាំងពលកម្មដែលមានតំលៃថោករបស់អ្នកជួញដូរ ។ គ្រួសារទាំងនោះ ដែលជាទូទៅប្រកបរបរកសិកម្មដែលត្រឹមតែគ្រប់គ្រាន់សំរាប់ចិញ្ចឹមជីវិត ត្រូវបានគេប្រាប់ថា កូនរបស់គេនឹងទទួលបាននូវការអប់រំ និងជំនាញធ្វើអាជីវកម្មដែលមានប្រយោជន៏ ។ នៅក្នុងករណីក៏ច្រើនលើសលប់ក្មេងនោះត្រូវបានគេជួញដូរទៅក្នុងស្ថានភាពនៃការបំរើសេវាកម្មក្នុងផ្ទះដែលមានលក្ខណះបង្ខឹតបង្ខំ ការលក់ដូរតាមចិញ្ចើមផ្លូវ រឺក៏ការកេងប្រវ័ញ្ចផ្លូវភេទ ។ ជាការឆ្លើយតប រដ្ឋាភិបាលប្រទេសហ្គាណាបានធ្វើ "ប្រតិបត្តិការយកកូនអ្នកមកផ្ទះវិញ" ដើម្បីជំរុញអោយឪពុកម្តាយដែលបានលក់កូនខ្លួនអោយទៅអ្នកជួញដូរនោះ យកកូនមកផ្ទះវិញដើម្បីជាថ្នូរនឹងជំនួយសំរាប់ធ្វើពាណិជកម្ម ការបណ្ដុះបណ្ដាលការងារ កម្ចីមីក្រូឥណទាន និងជំនួយសំរាប់ថ្លៃសាលានិងឯកសណ្ឋាន ។ ដើម្បីលើកកំពស់ការយល់ដឹងជាសាធារណះអំពីកម្មវិធីនេះ ប៉ូលីសហ្គាណាបានធ្វើការប្រជុំផ្តល់ពតិមាននៅតាមចំនតរថយន្តធំ៧ក្នុងតំបន់អាក្រា ដើម្បីអប់រំដល់អ្នកបើកបររថយន្តនិងតំណាងសហជីពដឹកជញ្ជូន អំពីការកំនត់រកជនរងគ្រោះ ។

<u>**ការដកហូតមូលនិធិដើម្បីឧបត្ថម្ភដល់កម្មវិធីប្រឆាំងការជួញដូរ**</u> មូលនិធិសំរាប់កម្មវិធីប្រឆាំងការជួញដូរគឺជាអាទិភាពថ្នាក់ទាបសំរាប់ប្រទេសជាច្រើន ជាពិសេសបន្ទាប់ពីមានការបង្វែរធនធានទៅលើកម្មវិធីប្រឆាំងនឹងអំពើភេរវកម្មវិញនោះ ។ រដ្ឋបាដិនវ៉ែតតំប៉ើកនៃប្រទេសអាល្លឺម៉ង់ប្រើប្រាស់មូលនិធិដែលរឹបអូសបានពីប្រតិបត្តិការជួញដូរមនុស្សដើម្បីទៅផ្គត់ផ្គង់លើការស៊ើបអង្កេតបន្តទៀត ។

<u>**ការផ្សារភ្ជាប់បណ្តាញអ្នកការទូត និងបែងចែកពតិមានសំងាត់**</u> ក្រសួងការបរទេសនៃសាធារណរដ្ឋដូមីនិកបានបង្កើតបណ្តាញប្រឆាំងការជួញដូរចំនួន៤ ក្នុងចំនោមអ្នកការទូតនៃស្ថានកុងស៊ុលនិងស្ថានទូតក្នុងបណ្តាប្រទេសសំខាន់៧ដែលទទួលយកស្រ្តីដូមីនិកដែលត្រូវបានគេជួញដូរ ។ មានបណ្តាញមួយនៅអាមេរិកកណ្តាល តំបន់សមុទ្រការីបង់ អាមេរិកខាងត្បូង និងអឺរុប ។ អ្នកការទូតទាំងនោះព្យាយាមទប់ស្កាត់ជាមុនក្នុងការដោះស្រាយបញ្ហាការជួញដូរ ។ ពួកគេធ្វើការជាមួយនឹងរដ្ឋាភិបាលនៃប្រទេសទាំងនោះ ដើម្បីកំនត់រកនឹងផ្តល់ជំនួយដល់ជនរងគ្រោះជាតិដូមីនិក (ដែលភាគច្រើនបានគេចចេញពីពួកអ្នកជួញដូរ ហើយរត់ទៅស្ថានកុងស៊ុលរបស់គេដើម្បីរកជំនួយ) ដើម្បីប្រមូលពតិមានអំពីបែបបទនៃការជួញដូរ និងដើម្បីរើកមុខអ្នកជួញដូរ ។ ពតិមាននេះត្រូវបានគេរាយការណ៍ទៅការិយាល័យកិច្ចការកុងសុលរបស់ក្រសួងការបរទេស និងត្រូវបានគេចែកចាយទៅសម្ព័ន្ធមិត្តក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូររបស់សាធារណរដ្ឋដូមីនិក ។

ការប្រើប្រាស់ឧបករណ៍ច្បាប់ អធិការកិច្ច និងបណ្តុះបណ្តាល រដ្ឋាភិបាលហ្វីលីពីនបានចេញបទបញ្ជា និងធ្វើអធិការកិច្ចវាយឆ្មក់ក៏ដូចជាប្រចាំ ទៅលើភ្នាក់ងារនាំចេញកំលាំងពលកម្មដែលមានច្បាប់ចំនួន ១៣១៧ ។ រដ្ឋាភិបាលក៏បានផ្តល់ផងដែរនូវការបណ្តុះបណ្តាល និងការសាកល្បងជំនាញ ដល់ពលករបរទេសទៅក្រៅប្រទេស មុនពេលពួកគេចាកចេញពីហ្វីលីពីន ។ មន្ត្រីសេវាកម្មបរទេសរបស់ហ្វីលីពីនត្រូវបានហ្វឹកហ្វឺន ហើយនៅក្នុងករណីខ្លះបានចូលរួមយ៉ាងសកម្មក្នុងការស្វែងរកផ្ទះសំបែង និងធ្វើមាតុភូមិនិវត្តន៍ជនជាតិហ្វីលីពីនដែលបានរងគ្រោះដោយការជួញដូរ ។ ហ្វីលីពីនបានផ្តល់ការបណ្តុះបណ្តាលលើវិធីពង្រឹងការការពារការនាំចេញកំលាំងពលកម្ម ដល់រដ្ឋាភិបាលដទៃទៀតនៅក្នុងតំបន់ រួមមានឥណ្ឌូនេស៊ី និងវៀតណាម ។

ជនរងគ្រោះទទួលបានការការពារផ្នែកការទូត ក្រសួងបរទេសឥណ្ឌូនេស៊ីបានបង្កើតទីជំរកនៅក្នុងស្ថានទូតនិងស្ថានកុងសុលរបស់ខ្លួននៅក្នុងប្រទេសមួយចំនួន រួមមានប្រទេសម៉ាឡេស៊ី សឹង្ហបុរី អារាប៊ីសាអូឌីត និងប្រទេសគុយវេត ។ ក្នុងឆ្នាំកន្លងមកនេះ អគារការទូតទាំងនេះ បានផ្តល់ទីជំរកដល់ពលរដ្ឋឥណ្ឌូនេស៊ីច្រើនពាន់នាក់ ដែលអ្នកខ្លះគឺជាអ្នកដែលអាចធ្លាក់ខ្លួនជាជនរងគ្រោះ ។ បេសកកម្មការទូតរបស់ឥណ្ឌូនេស៊ីដោយរួមសហការណ៍ជាមួយនឹងភ្នាក់ងារដទៃទៀតរបស់រដ្ឋាភិបាល ក៏បានជួយផងដែរក្នុងការធ្វើមាតុភូមិនិវត្តន៍ ។

ការប្រយុទ្ធនឹងការជួញដូរក្មេងអោយធ្វើជាអ្នកជិះអូដប្រណាំង រដ្ឋាភិបាលនៃសហព័ន្ធអារ៉ាប់អេមីរេត បានចាប់ផ្តើមនូវការអនុវត្តន៍បែបថ្មីមួយដើម្បីកំណត់រកនិងជួយសង្គ្រោះក្មេងដែលត្រូវគេជួញដូរពីអាស៊ីខាងត្បូង អោយធ្វើជាអ្នកជិះសត្វអូដប្រណាំងនៅលើទីលានប្រណាំងនៃសហព័ន្ធអារ៉ាប់អេមីរេត ។ កុមារទាំងនេះភាគច្រើនត្រូវបានគេជួញដូរតាមរយៈការប្រើឯកសារក្លែងក្លាយពីប្រទេសគេ ដោយបញ្ជាក់ពីអាយុពន្លើស និងឪពុកម្តាយក្លែងក្លាយដែលធ្វើដំនើរជាមួយកុមារទាំងនោះមកសហព័ន្ធអារ៉ាប់អេមីរេត ។ ដោយប្រើការធ្វើតេស្តឌីអែនអេដែលបានចាប់ផ្តើមនៅខែមករាឆ្នាំ២០០៣ អាជ្ញាធរសហព័ន្ធអារ៉ាប់អេមីរេតបានធ្វើតេស្តលើកុមារចំនួន៤៨៦នាក់ និងបានរកឃើញករណីដែលអ្នកជួញដូរដែលនាំកុមារទាំងនោះមកសហព័ន្ធអារ៉ាប់អេមីរេតអះអាងថាជាឪពុកម្តាយចំនួន៦៥ករណី ។ នៅឆ្នាំ២០០៣ កុមារជាង២៥០នាក់មកពីប្រទេសបង់ក្លាដេសនិងប៉ាគីស្ថានត្រូវបានគេរកឃើញនិងបញ្ជូនទៅប្រទេសដើមវិញ ហើយអ្នកជួញដូរជាច្រើននាក់ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ទោស ។ ប្រទេសដទៃទៀតនៅតំបន់ឈូងសមុទ្រកំពុងតែចាប់យកវិធីធ្វើតេស្តឌីអែនអេទៅលើកុមារជិះអូដប្រណាំង និងអ្នកដែលគេអះអាងថាជាឪពុកម្តាយ ។

វីរជនដែលធ្វើសកម្មភាពដើម្បីបញ្ឈប់ទាសភាពក្នុងសម័យកាលថ្មី

សកម្មភាពរបស់រដ្ឋាភិបាល ដូចដែលបានកំនត់ដោយច្បាប់ គឺជាចំនុចសំខាន់នៃរបាយការណ៍ស្តីពីការជួញដូរមនុស្ស ។ ទោះជាយ៉ាងនេះក៏ដោយ បន្ថែមពីលើរដ្ឋាភិបាល នៅមានមនុស្សនិងអង្គការជាច្រើនមកពីគ្រប់ស្រទាប់វណ្ណៈ កំពុងតែធ្វើសកម្មភាពយ៉ាងខ្លាំងក្លានិងប្រកបដោយប្រសិទ្ធភាពក្នុងការបញ្ឈប់ការជួញដូរមនុស្ស ។

ការទទួលបាននូវការចូលរួមយ៉ាងទូលំទូលាយពីមជ្ឍដ្ឋានផ្សេងៗគ្នាក្នុងការប្រយុទ្ធនេះ គឺជាកត្តាចាំបាច់ណាស់សំរាប់ទទួលបានជោគជ័យ ។ នេះហើយគឺជាមូលហេតុដែលរបាយការណ៏ឆ្នាំនេះមានរួមបញ្ចូលទាំងរឿងរ៉ាវនៅខាងក្រោមដែលនិយាយពីវីរជនទាំងឡាយនៅក្នុងកិច្ចប្រឹងប្រែងរបស់គេដើម្បីប្រឆាំងនឹងការជួញដូរមនុស្ស ។ បុគ្គលទាំងឡាយនៅក្នុងរបាយការណ៍នេះគឺគ្រាន់តែជាតំណាងនៃកិច្ចប្រឹងប្រែងជាច្រើនរបស់ពលរដ្ឋសាមញ្ញនៅទូទាំងពិភពលោកប៉ុណ្ណោះ ។ គេបានផ្តល់ជាឧទាហរណ៏សំរាប់យើងទាំងអស់គ្នា និងបង្ហាញថាការប្រឹងប្រែងរបស់បុគ្គលម្នាក់តែងតែអាចនាំអោយមានការផ្លាស់ប្តូរ ។ នៅមានមនុស្សជាច្រើនទៀតដែលបន្តការប្រយុទ្ធនឹងការជួញដូរជារៀងរាល់ថ្ងៃតាមវិធីផ្ទាល់ខ្លួនរបស់គេ ។

លោកព្យែរ តាមី

នាយកអង្គការ ហាហ្កា, កម្ពុជា

លោកព្យែរ តាមីបានប្រើវិធីសាស្ត្ររបស់អ្នកជំនួញជនជាតិស្វីសក្នុងការជួយជនរងគ្រោះដោយការជួញដូរមនុស្សនៅប្រទេសកម្ពុជា ។ ក្នុងទស្សនៈរបស់គាត់ កម្មវិធីជំនួយត្រូវតែប្រកបដោយគំនិតថ្មីៗ និងមានចេរភាពផ្នែកហិរញ្ញវត្ថុ ដើម្បីអោយអ្នកដែលមានអតីតភាពជាជនរងគ្រោះមានឱកាសក្នុងការផ្លាស់ប្តូរជីវិតទៅរកភាពប្រសើរឡើង ជាជាងនៅតែបន្តឋិតក្នុងភាពងាយនឹងត្រូវបានគេកេងប្រវ័ញ្ចជារៀងរហូតទៅ ។ លោក តាមី បានជួយបង្កើតសហគ្រាសដែលអាចជួយដល់ជនរងគ្រោះចំនួន៣នៅក្នុងទីក្រុងភ្នំពេញៈ រោងចក្រផលិតទឹកសណ្តែកសៀងមួយ ដែលបានបញ្ជូនអាហារត្រូវការចាំបាច់ទៅប្រទេសមួយដែលខ្វះអាហារូបត្ថម្ភ, ក្រុមហ៊ុនផលិតនិងរចនាសូត្រដែលមានគុណភាពខ្ពស់មួយ និងហាងអាហារមួយដែលបំរើអាហារសំរាប់កម្មករ រោងចក្រកាត់ដេរ ។ សហគ្រាសទាំងនេះកំពុងតែផ្តល់នូវក្តី

សង្ឃឹមថ្មីដល់ប្រជាជនកម្ពុជាដែលបានរងទុក្ខទោស ដោយសារទោសភាពសម័យថ្មីនេះ និងអនុញ្ញាតអោយពួកគេខ្លះទទួលបាននូវប្រាក់កាសពីការងាររបស់គេជាលើកដំបូងក្នុងជីវិត ។

ឯកឧត្តមហ្វ្រាង់ស៊ីស្កូ សៀវ៉ា

អគ្គរដ្ឋទូតប្រទេសកូឡុមប៊ី ប្រចាំប្រទេសជប៉ុន

ហ្វ្រង់ស៊ីស្កូ សៀវ៉ាបានបូជាការយកចិត្តទុកដាក់របស់គាត់ និងបុគ្គលិកស្ថានទូតទាំងអស់ ក្នុងការជួយដល់ជនងរងគ្រោះដោយការជួញដូរមនុស្សដែលត្រូវបានគេនាំយកពីប្រទេសកូឡុមប៊ីមកប្រទេសជប៉ុន ។ គាត់បានទាញអាជ្ញាធរប៉ូលីសមូលដ្ឋាន និងរដ្ឋាភិបាលជប៉ុន អោយមកប្រឡូកនឹងបញ្ហានេះ ហើយបានជំរុញអោយមន្ត្រីកូឡុមប៊ីដាក់បញ្ហានេះជាបញ្ហាអាទិភាពសំរាប់ប្រទេសកូឡុមប៊ី ។ គាត់បានជំរុញអោយមានកិច្ចសហប្រតិបត្តិការនៅក្នុងប្រទេសជប៉ុនរវាងបណ្តាស្ថានទូតនៃប្រទេសអាស៊ីអាគ្នេយ៍ខ្លះ និងប្រទេសអាមេរិកឡាទីន ។ លោកអគ្គរដ្ឋទូតសៀវ៉ាបានមើលឃើញនូវទស្សនៈវិស័យទាំងមូល និងជាផ្នែកតូចៗនៃបញ្ហាការជួញដូរមនុស្សៈ គាត់បានមើលឃើញពីការបំផ្លិចបំផ្លាញដែលកើតមានចំពោះបុគ្គល ប៉ុន្តែគាត់ក៏បានមើលឃើញអំពីទំនាក់ទំនងជាមួយនឹងឧក្រិដ្ឋកម្មឆ្លងដែន និងភាពស្មុគស្មាញនៃរូបភាពនៃការជួញដូរដែលតែងតែផ្លាស់ប្តូរជានិច្ចនោះដែរ ។

ដូនជីយូជីនៀ បូនេទី

សហជីពមួយរបស់អ៊ីតាលី

យូជីនៀ បូនេទី ទទួលបន្ទុកលើសកម្មភាពប្រឆាំងការជួញដូរមនុស្សរបស់សហជីពអ៊ីតាលីមួយ ។ គាត់មានការប្តេជ្ញាចិត្តខ្ពស់ ក្នុងការប្រយុទ្ធនឹងភាពអយុត្តិធមិដែលស្ត្រីដែលត្រូវគេជួញដូរបានទទួល ដោយសារតែអ្វីដែលគាត់បានឃើញផ្ទាល់ភ្នែកនៅក្នុងអាជីពជាសាសនទូតរយៈពេល២៤ឆ្នាំរបស់គាត់នៅក្នុងប្រទេសកេនយ៉ា ហើយបន្ទាប់មកជាអ្នកសំរបសំរួលយុទ្ធសាស្ត្រប្រឆាំងការជួញដូរនៅក្នុងទីក្រុងទូរីន និងរ៉ូម ។ ដូនជីយូជីនៀ និងក្រុមរបស់គាត់ ដែលមានដូនជីប្រហែលជា២០០នាក់នៅទូទាំងប្រទេសអ៊ីតាលី ធ្វើការងារពេញម៉ោងក្នុងកិច្ចផ្តួចផ្តើមប្រឆាំងនឹងការជួញដូរមនុស្ស បានយកផ្ទះខ្លួនគេផ្ទាល់ដើម្បីផ្តល់ជាទីជំរក សន្តិសុខ

និងការថែរក្សាដល់ ជនរងគ្រោះពីការជួញដូរជាច្រើនរយនាក់ ។ ដូនជីយូជីនៀ នៅបានធ្វើការជាមួយនឹងដូនជីក្នុងប្រទេសនីហ្សេរីយ៉ា ដោយជំរុញអោយមានការខិតខំនៅតាមមូលដ្ឋាននៃសហគមន៍ដែលដាច់ស្រយាល និងក្រីក្របំផុត ដើម្បីទប់ស្កាត់ការជួញដូរ និងដើម្បីជួយស្តារនីតិសម្បទាជនរងគ្រោះ ដែលត្រូវបានគេបញ្ជូនមកវិញ ។ ដូនជីយូជីនៀកំពុងផ្សព្វផ្សាយសារ ជាពាក្យពេចន៍និងជាសកម្មភាពជាក់ស្តែង ស្តីអំពីការប្រឆាំងនឹងការជួញដូរទាំងនៅក្នុង និងក្រៅប្រទេស ។

បូនី មៀល័រ

ពលរដ្ឋអាមេរិក

បូនី មៀល័រ បានធ្វើសកម្មភាពជាច្រើនដើម្បីប្រយុទ្ធនឹងការជួញដូរមនុស្សអោយមានប្រសិទ្ធភាពនៅក្នុងប្រទេសក្រិច ដោយបានចំនាយពេលជាច្រើនរាប់មិនអស់របស់គាត់ ក្នុងការទាក់ទាញចំនាប់អារម្មណ៍ និងធនធានសំរាប់បញ្ហាជួញដូរនេះ ។ គាត់បានជួយអង្គការក្រៅរដ្ឋាភិបាលរបស់ក្រិចបង្កើតសេវាកម្មសំរាប់ជនរងគ្រោះ បញ្ចុះបញ្ចូលរដ្ឋាភិបាលអោយធ្វើសកម្មភាពអោយបានខ្លាំងក្លាក្នុងការប្រឆាំងអំពើជួញដូរមនុស្ស និងបានបង្កើតប្រព័ន្ធទូរស័ព្ទបន្ទាន់សំរាប់ការជួញដូរដំបូងបង្អស់ នៅក្នុងប្រទេសក្រិច ។ អ្នកស្រីមៀល័រគឺជាជើងឯកនៅក្នុងបុព្វហេតុប្រឆាំងនឹងការជួញដូរមនុស្ស តាមរយៈការប្រឹងប្រែងតាមប្រព័ន្ធឃោសនា និងបាននាំអ្នកការទូតមកពីប្រទេសជាច្រើនមកជួបគ្នាពិភាក្សាពីមធ្យោបាយជួយជនរងគ្រោះដោយការជួញដូរមនុស្ស ។ គាត់នៅបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតទីជំរកសំរាប់ជនរងគ្រោះឈ្មោះថា វេជ្ជបណ្ឌិតសំរាប់ពិភពលោក ។ ជាភរិយារបស់លោកអគ្គរដ្ឋទូតប្រចាំ ប្រទេសក្រិច លោកថូម៉ាស់ មៀល័រ អ្នកស្រីក៏បានបង្ហាញអោយឃើញផងដែរ អំពីវិធីដែលគ្រួសាររបស់អ្នកការទូតអាចជួយផ្លាស់ប្តូរសហគមន៍ដែលគេរស់នៅ ។

លោកប្រធាន ថូបេហ្កា ហាដជ័រ

នូបាកប៉ា ប្រទេសហ្កាណា

លោកប្រធាន ថូបេហ្កា ហាដជ័រ បានធ្វើការងារជាច្រើនដើម្បីបញ្ឈប់ការជួញដូរពលកម្មកុមារនៅក្នុងតំបន់ឡេកវ៉ុលតានៃប្រទេសហ្កាណា។ ក្នុងឆ្នាំកន្លងមកនេះ កុមារចំនួន២២៨នាក់ត្រូវបានសង្គ្រោះពីការងារ ដោយបង្ខិតបង្ខំនៅក្នុងឧស្សាហកម្មនេសាទមួយ ដោយមានជំនួយផ្ទាល់ពីលោកហាដជ័រក្នុងការកំនត់តំបន់ដែលគេស្គាល់ថាជាកន្លែងជួញដូរកុមារ។ គាត់បានជួយក្នុងការធ្វើសមាហរណកម្មកុមារដែលជាទាសករទាំងនេះ ដោយអោយពួកគេចូលសាលារៀន និងធ្វើអោយគេជួបជុំគ្រួសារវិញ។ គាត់បានធ្វើការដោយផ្ទាល់ក្នុងការរៃអង្គាសមូលនិធិមីក្រូឥណទានសំរាប់អោយឪពុកម្តាយពង្រីកមុខរបររបស់គេដើម្បីអោយគេមានលទ្ធភាពអាចផ្តល់អោយសមាជិកគ្រួសារគេបានប្រសើរជាងនេះ។

ម៉ារីលីន ខាលសិន នែលសិន

ប្រធាន និងនាយកប្រតិបត្តិនៃក្រុមហ៊ុន ខានសិន

ម៉ារីលីនខាលសិនបានក្លាយជាជនជាតិអាមេរិកដំបូង ដែលបានត្រួសត្រាយផ្លូវសំរាប់ការប្រឆាំងនឹងការជួញដូរមនុស្ស នៅពេលដែលគាត់បានធ្វើក្រុមហ៊ុនទេសចរណ៍ទាំងឡាយរបស់គាត់អោយស្របតាមក្រមសីលធមិជាសកលដែលព្យាយាមការពារកុមារពីការកេងប្រវ័ញ្ចអាជីវកម្មផ្លូវភេទនៅក្នុងការធ្វើដំណើរនិង វិស័យទេសចរណ៍។ ជាផ្នែកមួយនៃក្រមសីលធមិ ដែលអ្នកស្រីនែលសិនបានចុះហត្ថលេខា គាត់បានយល់ព្រមបណ្តុះបណ្តាលបុគ្គលិករបស់គាត់អោយវែកមុខនិងរាយការណ៍អំពីអ្នកធ្វើទេសចរណ៍ផ្លូវភេទលើកុមារ ប្រាប់ទៅអ្នកដំណើរអំពីទណ្ឌកម្មផ្នែកច្បាប់ទាក់ទងនឹងការរំលោភបំពានបែបនោះ និងបង្កើតជាគោលការណ៍ក្រមសីលធមិសាជីវកម្មបដិសេធមិនទទួលស្គាល់ការកេងប្រវ័ញ្ចផ្លូវភេទនៅក្នុងវិស័យទេសចរណ៍។ ក្រុមហ៊ុន ខាលសិន ដែលមានសេវាកម្មជាច្រើន រួមមានបណ្តាញសណ្ឋាគារ ដំណើរកំសាន្តតាមនាវាលើសមុទ្រ ភោជនីយដ្ឋាន ហើយនិងជាភ្នាក់ងារទេសចរណ៍ដែលធំបំផុតទី២នៅលើពិភពលោក បានលក់បានជាង ២៧កោដិដុល្លារកាលពីឆ្នាំមុន និងផ្តល់ការងារដល់បុគ្គលិកប្រមាណជា

១៩៨000នាក់ នៅក្នុងប្រទេសជាង១៤0 ។ ក្រុមហ៊ុនខាលសិនគឺជាក្រុមហ៊ុនទេសចរណ៏ធំនៅអាមេរិកខាងជើងដំបូងគេដែលបានអនុវត្តក្រមសីលធម៌នេះ ។